# ហេតុអ្វីបានជាជ្រើសរើសសាលាមធ្យមសិក្សារដ្ឋ?

## ព័ត៌មានសំរាប់មាតាបិតា និងអ្នកមើលថែ







សាលាមធ្យមសិក្សារដ្ឋរៀបចំក្មេងជំទង់ ដើម្បីឲ្យគេរស់នៅក្នុងជីវិតមនុស្សពេញវ័យបានពេញលេញ ហើយជាទីពេញចិត្ត ព្រមទាំងចេះដោះស្រាយ ហើយពុះពារនៅក្នុងពិភពលោកសព្វថ្ងៃ។

### ការបង្រៀន និងការសិក្សាដែលមានគុណភាព

សាលារៀននៅក្នុងប្រព័ន្ធសិក្សារដ្ឋ NSW ប្រើ NSW Quality Teaching Framework (ក្របខ័ណ្ឌបង្រៀនដែលមានគុណភាពនៅរដ្ឋ NSW) ជាក្របខ័ណ្ឌអនុវត្តលើការបង្រៀន ការសិក្សា និងការឲ្យពិន្ទុដែលលើកស្ទួយលទ្ធផលការសិក្សាសំរាប់សិស្ស ដើម្បីផ្តល់នូវការបង្រៀន និងការសិក្សាដែលជាទីចាប់ចិត្ត មានការទាក់ទិន ហើយមានការពុះពារ។ គ្រូបង្រៀនរបស់យើងមានការហ្វឹកហ្វឺនពេញលេញ ហើយមានគុណសម្បត្តិគ្រប់គ្រាន់ពីឧត្តមសិក្សា។ សាលារៀនរបស់យើងក៏មានប្រើអ្នកផ្តល់ឱវាទឯកទេស ដែលផ្តល់ឱវាទ និងការហ្វឹកហ្វឺនដល់គ្រូបង្រៀនជាទៀងទាត់ ដើម្បីធ្វើយ៉ាងណារក្សាការបង្រៀន និងការសិក្សារបស់យើងនៅក្នុងថ្នាក់រៀនឲ្យមានកំរិតខ្ពស់បំផុត។

### ឱកាសទទួលយកកម្មវិធីការសិក្សាដ៏ធំទូលាយ

សាលាមធ្យមសិក្សារដ្ឋ NSW ផ្តល់ដល់សិស្សនូវមុខវិជ្ជាសិក្សា ឱកាស និងជំនាញការដែលមានទំហំធំទូលាយ។ តាមរយៈឱកាសទទួលយកការសិក្សា និងការហ្វឹកហ្វឺនខាងវិជ្ជាជីវៈ សិស្សរបស់យើងមិនគ្រាន់តែសិក្សាមុខវិជ្ជាច្រើនផ្សេងៗតាមសាលារៀនប៉ុណ្ណោះទេ គេក៏អាចប្រើកម្មវិធីសិក្សាផ្សេងៗទៀតភាគច្រើនផ្តល់ឲ្យដោយមានសហការជាមួយវិទ្យាស្ថាន TAFE។ សិស្សដែលមានវ័យចំណាស់ក៏អាចសិក្សាមុខវិជ្ជាកំរិតសាកលវិទ្យាល័យផងដែរ ដែលតភ្ជាប់ទៅនឹង HSC (វិញ្ញាបនបត្រចំពោះការបំពេញដោយជោគជ័យនៃសេចក្តីតម្រូវផ្នែកកម្មវិធីសិក្សា Year 11 និង Year 12)។ មានសាលារៀនជាច្រើននៅតាមជនបទ និងទីដាច់ស្រយាល ដែលប្រើកុំព្យូធើរភ្ជាប់ ដើម្បីផ្តល់មុខវិជ្ជាបន្ថែម។

### តម្លៃដ៏រឹងមាំ

សាលាមធ្យមសិក្សារដ្ឋប្រចាំតំបន់របស់លោកអ្នកនឹងបន្តនូវការសិក្សាដែលមានតម្លៃសំខាន់ ដែលបានចាប់ផ្តើមនៅក្នុងសាលាបឋមសិក្សារបស់កូនលោកអ្នក។ នេះគឺជាការសំខាន់ចាំបាច់ដែលសិស្សរបស់យើងបានយល់ច្បាស់អំពីសារៈសំខាន់នៃការគោរព ការទទួលខុសត្រូវ ភាពថ្លៃថ្នូរ ឧត្តមភាព គំនិតទូលំទូលាយ ការធ្វើសហការ ការចូលរួម ការយកចិត្តទុកដាក់ ភាពត្រឹមត្រូវ ហើយនិងលិទ្ធិប្រជាធិបតេយ្យ។ ធ្វើដូច្នេះដើម្បីឲ្យយើងអាចជួយកូនរបស់លោកអ្នកៈ

- ពង្រីកការស្រឡាញ់ដល់ការរៀនសូត្រ
- ដេញតាមយកកំរិតសិក្សាដែលមានភាពល្អវិសេស ហើយមានកំរិតខ្ពស់
- ពង្រីកនូវការយកចិត្តទុកដាក់ និងការគោរពដល់ខ្លួនគេ និងអ្នកដទៃ
- ពេញចិត្តនឹងកិច្ចការរបស់គេ
- បញ្ចេញឲ្យឃើញនូវគំនិតត្រឹមត្រូវ និងយុត្តិធម៌សង្គម
- ឲ្យតម្លៃដល់ប្រវត្តិសាស្រ្តរបស់ប្រទេសអូស្រ្តាលី និងសង្គមពហុវប្បធម៌
- ចូលរួមយ៉ាងសកម្មក្នុងភាពជាពលរដ្ឋ។

## កិច្ចបំរើគាំទ្រដែលល្អវិសេស

កម្លាំងមួយដ៏សំខាន់នៃប្រព័ន្ធសាលារៀនរដ្ឋគឺមានបណ្តាញទូលំទូលាយនៃពួកមនុស្សដែលធ្វើការដើម្បីធ្វើយ៉ាងណាឲ្យក្មេងម្នាក់ៗសម្របសម្រួលបានដោយជោគជ័យ នៅក្នុងបរិយាកាសសាលារៀនថ្មីរបស់គេ។ កិច្ចបំរើគាំទ្រផ្សេងៗដ៏ច្រើនដែលជួយសិស្សរកផ្លូវដោះស្រាយការផ្លាស់ប្តូររបស់គេចូលទៅឯសាលាមធ្យមសិក្សា មានរួមទាំង:

- អ្នកប្រឹក្សាសិស្ស
- អ្នកប្រឹក្សាលើមុខអាជីព
- ក្រុមសុខុមាលភាពសិស្ស
- អ្នកប្រឹក្សាសាលារៀនដែលមានសមត្ថភាពគ្រប់គ្រាន់
- គ្រូបង្រៀនជំនួយសំរាប់សិស្សដែលមានការលំបាកនឹងការរៀនសូត្រ
- គ្រូបង្រៀនភាសាអង់គ្លេសជាភាសាទីពីរ
- អ្នកជំនួយការរៀនសូត្រសំរាប់ជនជាតិដើម
- បុគ្គលិកខាងព័ត៌មាន និងទំនាក់ទំនងសហគមន៍។

## ការផ្តោតទៅលើថ្នាក់កណ្តាល (Year 5 ទៅ Year 9)

ការជួយសិស្សនៅក្នុង 'ថ្នាក់កណ្តាល' របស់សិស្សត្រូវបានសម្គាល់ឃើញថាជាអាទិភាពពេញទូទាំងការសិក្សាអប់រំរដ្ឋនៅក្នុងរដ្ឋ NSW។ សាលារៀនបានរៀបចំឲ្យមានកម្មវិធីថ្នាក់កណ្តាលប្រកបដោយជោគជ័យយ៉ាងខ្ពស់ ដើម្បីធ្វើឲ្យប្រាកដថាការផ្លាស់ប្តូរទីកន្លែងរបស់សិស្ស និងមាតាបិតាចូលទៅសាលាមធ្យមសិក្សាមានភាពងាយ ហើយស្រួលបំផុតដែលអាចធ្វើទៅបាន។

**លទ្ធផលផ្នែកការសិក្សាខ្ពស់ ការបង្រៀន និងការសិក្សាដែលមានគុណភាព ឱកាសទទួលយកកម្មវិធីសិក្សាដ៏ទូលំទូលាយ តម្លៃដ៏រឹងមាំ កិច្ចបំរើគាំទ្រដ៏ល្អវិសេស និងការផ្តោតទៅលើថ្នាក់កណ្តាល – គឺជាមូលហេតុដ៏ល្អប្រាំមួយដើម្បីចុះឈ្មោះកូនរបស់លោកអ្នកចូលរៀននៅសាលាមធ្យមសិក្សារដ្ឋ។**

## កិច្ចបំរើអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា ដើម្បីជួយលោកអ្នកទាក់ទងជាមួយនាយកសាលា សូមទូរស័ព្ទទៅកិច្ចបំរើអ្នកបកប្រែភាសាលេខ 131 450 ហើយស្នើសុំអ្នកបកប្រែភាសាជាភាសារបស់លោកអ្នក។ នៅពេលនោះអ្នកបកប្រែភាសានឹងទូរស័ព្ទទៅនាយកសាលា ហើយនិងជួយលោកអ្នកក្នុងការសន្ទនាតាមទូរស័ព្ទ។ លោកអ្នកនឹងមិនបង់ថ្លៃសំរាប់កិច្ចបំរើនេះទេ។

NSW Department of Education

GPO Box 33
Sydney NSW 2001
T 9561 8000

Education
Public Schools

KHMER